**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨-០១២-៤១៤ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១២

# សេចក្តីជូនដំណឹង
## ស្តីពី
## កាលបរិច្ឆេទសម្រាប់ការប្រឡងជ្រើសរើសបុគ្គលិក និងប្រឡងឆ្លងក្របខ័ណ្ឌ

-យោងលិខិតលេខធ.៨.០១២-២៣២.សជណ និងលិខិតលេខធ.៨.០១២-២៣៣.សជណ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការជ្រើសរើសបុគ្គលិកចូលបម្រើការងារនៅធនាគារជាតិនៃកម្ពុជា

-យោងលិខិតលេខធ.៨.០១២-៣៥០.សជណ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការផ្សព្វផ្សាយការប្រឡងឆ្លងចូលក្របខ័ណ្ឌមន្ត្រីក្រមការ

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់បេក្ខជនប្រឡងកម្រិតសញ្ញាបត្របរិញ្ញាបត្រផ្នែក**គណនេយ្យ** ឬ**ធនាគារ** កម្រិត**ប្រកាសនីយប័ត្រជាន់ខ្ពស់បច្ចេកទេសធនាគារ** ដែលបានដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅធនាគារជាតិនៃកម្ពុជា និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាដែលបានដាក់ពាក្យសុំ ប្រឡងឆ្លងចូលក្របខ័ណ្ឌមន្ត្រីក្រមការ អោយបានជ្រាបថា កាលបរិច្ឆេទសម្រាប់ការប្រឡងនឹងប្រព្រឹត្តទៅ **នៅថ្ងៃ សៅរ៍ ទី ១៨ ខែ សីហា ឆ្នាំ ២០១២** និងវិញ្ញាសាប្រឡងមានដូចខាងក្រោម ៖

ពេលព្រឹក ៖ + ចំណេះដឹងទូទៅ និងជំនាញធនាគារ
+ ជំនាញគណនេយ្យ

ពេលរសៀល ៖ + ភាសាអង់គ្លេស

- ទីកន្លែងប្រឡង ៖ ជូនដំណឹងនៅពេលក្រោយ។

- បេក្ខជនអាចមកទំនាក់ទំនងសាកសួរព័ត៌មានលំអិតបន្ថែមទៀត នៅនាយកដ្ឋានបុគ្គលិកនៃធនាគារជាតិនៃកម្ពុជា ចន្លោះពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ១៥:០០រសៀល រៀងរាល់ថ្ងៃធ្វើការ ។/.

**ត.ប.ទេសាភិបាល**
**អគ្គលេខាធិការ**

**ស៊ុំ-សន្និសិទ្ធ**